**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តកំពង់ធំ**

# សេចក្តីជូនដំណឹង

## ស្តីពី

## ការរៀបចំពិធីប្រណាំងទូកក្នុងខេត្តកំពង់ធំ ឆ្នាំ២០១៧

រដ្ឋបាលខេត្តកំពង់ធំ មានកិត្តិយស សូមជម្រាបជូនដំណឹងដល់ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាងកញ្ញា មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស បងប្អូនអាជីវករ សាធារណៈជន និងបងប្អូនប្រជាពលរដ្ឋទូទាំងខេត្តកំពង់ធំឲ្យបានជ្រាបថា ៖ ឆ្នាំនេះក៏ដូចឆ្នាំមុនៗដែរ ដើម្បីបង្កលក្ខណៈជូនបងប្អូនប្រជាពលរដ្ឋនិងសាធារណៈជន បាន កំសាន្តសប្បាយរីករាយក្នុងឱកាសបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក និងដើម្បីសម្រិតសម្រាំងយកទូកទៅចូលរួមព្រះរាជពិធីបុណ្យអុំទូកនៅមុខព្រះបរមរាជវាំង រាជធានីភ្នំពេញផងនោះ។ រដ្ឋបាលខេត្តកំពង់ធំ បានសម្រេចរៀបចំពិធីអុំទូកនៅខេត្តកំពង់ធំចំនួន ០២ថ្ងៃ ដែលនឹងប្រព្រឹត្តទៅនៅតាមបណ្តោយមាត់ស្ទឹងសែន (មុខវេទិកាអុំទូកខេត្ត) នៅថ្ងៃ ២រោច-៣រោច ខែ អស្សុជ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី០៧-០៨ ខែតុលា ឆ្នាំ២០១៧ខាងមុខនេះ ។ ម្យ៉ាងវិញទៀតនៅពេលរាត្រីក៏មានពិធីបណ្តែតប្រទីប ការប្រគុំតន្ត្រី សម្តែងទស្សនីយភាព របាំ ចម្រៀង និងបាញ់កាំជ្រួចជូនទស្សនាកំសាន្តផងដែរ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាងកញ្ញា មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស បងប្អូនអាជីវករ សាធារណៈជន និងបងប្អូនប្រជាពលរដ្ឋជ្រាបជាព័ត៌មាន និងចូលរួមកំសាន្តសប្បាយរីករាយឲ្យបានច្រើនកុះករ ។

ធ្វើនៅកំពង់ធំ ថ្ងៃទី២៧ ខែ កញ្ញា ឆ្នាំ២០១៧

**រដ្ឋបាលខេត្តកំពង់ធំ**